ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ១៧ សសរ

# សេចក្តីសម្រេច

## ស្តីពី

## ការបង្កើតគណៈកម្មការអន្តរក្រសួងដើម្បីត្រួតពិនិត្យការដូរឆ្នាំកំណើត និងកាំប្រាក់របស់មន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមតម្រូវការចាំបាច់

## សម្រេច

ប្រការ១៖ បង្កើតគណៈកម្មការអន្តរក្រសួងដើម្បីត្រួតពិនិត្យការដូរឆ្នាំកំណើត និងកាំប្រាក់ របស់មន្ត្រីរាជការដែលមានសមាសភាពដូចខាងក្រោមៈ

| | | | | |
|---|---|---|---|---|
| ១-ឯកឧត្តម | **វ៉េង** | **សិរីវុឌ្ឍ** | ទេសរដ្ឋមន្ត្រី | ប្រធាន |
| ២-ឯកឧត្តម | **អ៊ុក** | **រ៉ាប៊ុន** | រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជារដ្ឋលេខាធិការ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ( បំរុងឯកឧត្តម **មោក សុធារិន** អនុរដ្ឋលេខាធិការ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ) | សមាជិក |
| ៣-ឯកឧត្តម | **ពេជ្រ** | **ប៊ុនធិន** | រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ | សមាជិក |
| ៤-ឯកឧត្តម | **ង៉ោ** | **ហុងលី** | អគ្គលេខាធិការនៃក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល សមាជិក | អចិន្ត្រៃយ៍ |
| ៥-តំណាងក្រសួង ស្ថាប័នដែលគ្រប់គ្រងមន្ត្រីសាមី | | | | សមាជិក |

ប្រការ២៖ គណៈកម្មការអន្តរក្រសួងដើម្បីត្រួតពិនិត្យការដូរឆ្នាំកំណើត និងកាំប្រាក់ របស់មន្ត្រីរាជការ មានតួនាទី និងភារកិច្ចដូចតទៅ៖

-ពិនិត្យ ផ្ទៀងផ្ទាត់ លើឯកសារការដូរឆ្នាំកំណើត និងកាំប្រាក់របស់មន្ត្រីរាជការ

-ពិនិត្យស្រាវជ្រាវឯកសារពាក់ព័ន្ធព័ត៌មានមន្ត្រីរាជការស៊ីវិលក្នុងករណីចាំបាច់

-ធ្វើរបាយការណ៍ជូនរាជរដ្ឋាភិបាល តាមរយៈប្រធានក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល ។

ប្រការ៣៖ សមាសភាព គណៈកម្មការអន្តរក្រសួងដើម្បីត្រួតពិនិត្យការដូរឆ្នាំកំណើត និងកាំប្រាក់ របស់មន្ត្រីរាជការអាចធ្វើការកែសម្រួលបាននៅពេលមានតម្រូវការចាំបាច់ ។

ប្រការ៤៖ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ ក្រសួងស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងប្រការ ១ ខាងលើ ត្រូវអនុវត្តសេចក្តីសម្រេចនេះ ចាប់ពីថ្ងៃទីចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ០៤ ខែ មីនា ឆ្នាំ ២០០៩

នាយករដ្ឋមន្ត្រី

កន្លែងទទួល

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួងស្ថាប័ន
- ដូចប្រការ ៤
- ឯកសារ-កាលប្បវត្តិ

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន